**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ** **សាធារណៈ/Public**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 20-Mar-2013, 13:45
CMS/CFO: Ly Bunloung

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ចម្លើយតបទៅនឹង "សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នូវលិខិតពីរច្បាប់របស់អង្គការលើកលែងទោសអន្តរជាតិ ផ្ញើជូន ខៀវ សំផន និង អៀង សារី"**

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ូរ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

**ជំនួយការ៖**
លោកស្រី សេង សុជាតា
កញ្ញា Marie CAPOTORTO
កញ្ញា Shéhérazade BOUARFA
កញ្ញា Mathilde CHIFFERT
កញ្ញា អ៊ុច ស្រីផាត់
លោក Pierre TOUCHE
កញ្ញា Blandine ZELLER

ចៅក្រម យ៉ា សុខន
**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

## សេចក្តីផ្តើម

១. នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ភាគីទទួលបានការជូនដំណឹងពីសំណើរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង សុំដាក់ឲ្យពិភាក្សាដេញដោលនូវលិខិតពីរច្បាប់របស់អង្គការលើកលែងទោសអន្តរជាតិ ផ្ញើជូនលោក ខៀវ សំផន និងលោក អៀង សារី[1]។

២. សហព្រះរាជអាជ្ញារៀបចំសំណើរបស់ខ្លួនជាពីរវគ្គ ហើយចាប់ផ្តើម ដោយបញ្ជាក់ថាឯកសារដែលខ្លួនស្នើសុំដាក់ឲ្យពិភាក្សាដេញដោល មានភាពពាក់ព័ន្ធ រួចអះអាងថាសំណើរបស់ខ្លួនអាចទទួលយកបាន។

៣. ទង្វើបែបនេះ គឺមានន័យថា សហព្រះរាជអាជ្ញាធ្វើបញ្ច្រាសលំដាប់លំដោយគតិយុត្តិ។ ជាក់ស្តែង អង្គជំនុំជម្រះសាលាដំបូង (“អង្គជំនុំជម្រះ”) ត្រូវតែសម្រេចអំពីភាពអាចទទួលយកបាននៃសំណើ អនុលោមតាមវិធាន ៨៧(៤) ជាមុនសិន រួចទើបសម្រេចអំពីភាពអាចទទួលយកបាននៃឯកសារ ដោយពិនិត្យទៅលើភាពពាក់ព័ន្ធ អនុលោមតាមវិធាន ៨៧(៣)។

## I- ភាពមិនអាចទទួលយកបាននៃសំណើរបស់សហព្រះរាជអាជ្ញា

៤. សហព្រះរាជអាជ្ញាស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះ ឲ្យដាក់ពិភាក្សាដេញដោលនូវឯកសារថ្មីពីរ ដែលមិនស្ថិតនៅក្នុងបញ្ជីឯកសាររបស់ខ្លួន ប៉ុន្តែ មានស្រាប់នៅក្នុងសំណុំរឿងស៊ើបអង្កេត។

---

[1] សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវលិខិតពីរច្បាប់ ផ្ញើឡើងដោយអង្គការលើកលែងទោសអន្តរជាតិ (Amnesty International) ជូនចំពោះ ខៀវ សំផន និង អៀង សារី ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E265។

៥. សហព្រះរាជអាជ្ញាលើកឡើងថា ខ្លួនមិនចាំបាច់បំពេញតាមលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៤) នោះឡើយ ដោយសារតែឯកសារទាំងពីរនេះមាននៅក្នុងសំណុំរឿងស៊ើបអង្កេតស្រាប់។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាយល់ឃើញថាខ្លួនរួចផុតពីកាតព្វកិច្ចក្នុងការបង្ហាញថា ទោះបីជាមានការខ្នះខ្នែងអស់ពីលទ្ធភាពយ៉ាងណាក៏ដោយ ក៏ខ្លួនមិនអាចផ្តល់ឯកសារទាំងពីរនេះជូនភាគីបាន មុនពេលបើកសវនាការជំនុំជម្រះក្តី[2]។ បើតាមសហព្រះរាជអាជ្ញា បញ្ជីឯកសារដែលអង្គជំនុំជម្រះស្នើសុំពីភាគី មុនពេលបើកសវនាការជំនុំជម្រះក្តី គ្រាន់តែជាបញ្ជីចង្អុលបង្ហាញ មិនមែនជាបញ្ជីពេញលេញស្ថាពរនោះទេ[3]។

៦. ការបកស្រាយរបស់សហព្រះរាជអាជ្ញាផ្ទុយទៅនឹងសេចក្តីណែនាំរបស់អង្គជំនុំជម្រះ ហើយខុសគ្នាពីគោលជំហរមុនរបស់ខ្លួន។ ជាក់ស្តែង នៅពេលជំទាស់ទៅនឹងការដាក់បញ្ជីឯកសាររបស់មេធាវីការពារក្តីលោក នួន ជា សហព្រះរាជអាជ្ញាបានរំឭកថា អង្គជំនុំជម្រះបានចេញអនុស្សរណៈមួយចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ កំណត់ថា ឯកសារដែលមិនត្រូវបានបង្ហាញអត្តសញ្ញាណស្របតាមកាលកំណត់មុនៗអាចទទួលយកបាន ទាល់តែភាគីស្នើសុំបង្ហាញថាឯកសារនោះមិនអាចផ្តល់ជូនឆាប់ជាងនេះបាន ទោះបីជាមានការខ្នះខ្នែងអស់ពីលទ្ធភាពយ៉ាងណាក៏ដោយ ហើយឯកសារចាំបាច់ត្រូវតែទទួលយក ដើម្បីជាប្រយោជន៍យុត្តិធម៌[4]។

៧. នៅក្នុងអនុស្សរណៈដែលសហព្រះរាជអាជ្ញាយោងជាសំអាង អង្គជំនុំជម្រះបន្ថែមទៀតថា *"សំណើសុំឱ្យទទួលយកឯកសារភាគច្រើន ដែលដាក់យឺតពេល មានឱកាសតិចតួចស្តួចស្តើងក្នុងការទទួលបានការអនុញ្ញាត"*[5]។

---

[2] ឯកសារ E265 កថាខណ្ឌ ៩។

[3] ឯកសារ E265 កថាខណ្ឌ ១០។

[4] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបញ្ជីឯកសាររបស់ នួន ជា ដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅដំណាក់កាលដំបូងនៃការជំនុំជម្រះ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E131/1/14 កថាខណ្ឌ ៤ និងកថាខណ្ឌ ៦ (បកប្រែផ្ទៃក្នុង ដោយសារតែឯកសារនេះមាននៅក្នុងសំណុំរឿង តែជាភាសាអង់គ្លេស និងខ្មែរប៉ុណ្ណោះ)។

[5] បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះ នៅដំណាក់កាលដំបូង ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E131/1 ទំព័រ ៦។

៨. ដូចគ្នានេះដែរ នៅក្នុងសេចក្តីសម្រេចស្តីពីឯកសារថ្មី អង្គជំនុំជម្រះប្រកាសថា៖ *"ចំពោះ<u>ឯកសារទាំងអស់ដែលមិនមាននៅក្នុងបញ្ជីឯកសារដាក់ដោយភាគី</u> ស្របតាមដីកានានារបស់អង្គជំនុំជម្រះ អង្គជំនុំជម្រះសូមបញ្ជាក់ថា ភាគីនៅតែមានលទ្ធភាពក្នុងការដាក់ពាក្យសុំបង្ហាញឯកសារថ្មីនាពេលក្រោយទៀត អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ប្រសិនបើភាគីយល់ឃើញថាឯកសារថ្មីដែលខ្លួនស្នើសុំដាក់នោះ ផ្តល់ប្រយោជន៍ដល់យុត្តិធម៌"*[6]។

៩. ដូច្នេះ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ត្រូវយកមកអនុវត្តចំពោះស្ថានភាពនេះ៖
*"៤. ក្នុងអំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬតាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឲ្យបានច្បាស់លាស់។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧(៣) ខាងលើ។ ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ"*។

១០. ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាមិនបានបង្ហាញថា ទោះបីជាមានការខ្វះខ្នែងអស់ពីលទ្ធភាពយ៉ាងណាក៏ដោយ ក៏ខ្លួនមិនអាចផ្តល់ឯកសារទាំងពីរនេះជូនភាគីបាន មុនពេលបើកសវនាការជំនុំជម្រះក្តីទេ។ ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាមិនអាចធ្វើបាននោះទេ។ យ៉ាងណាមិញ លិខិតទាំងពីរច្បាប់នេះមាននៅក្នុងសំណុំរឿងស៊ើបអង្កេតស្រាប់ តាំងតែពីឆ្នាំ២០០៩ មកម្ល៉េះ ហើយឯកសារទាំងពីរនេះទៀតសោតត្រូវបានដាក់នៅក្នុងសំណុំរឿងស៊ើបអង្កេត តាមការស្នើសុំរបស់សហព្រះរាជអាជ្ញា។ ជាក់ស្តែង នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាបានស្នើសុំដាក់ក្នុងសំណុំរឿងនូវលិខិតបីច្បាប់របស់អង្គការលើកលែងទោសអន្តរជាតិ[7]។ លិខិតតែមួយប៉ុណ្ណោះក្នុងចំណោមលិខិត

---

[6] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E190 កថាខណ្ឌ ២១។

[7] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យដាក់ឯកសារពាក់ព័ន្ធនឹង ខៀវ សំផន ចំនួនបី បញ្ចូលក្នុងសំណុំរឿង និងសុំឲ្យចាត់កិច្ច

ចម្លើយតបទៅនឹង "សំណុំរបស់សហព្រះរាជអាជ្ញាសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នូវលិខិតពីរច្បាប់របស់អង្គការលើកលែងទោសអន្តរជាតិ ផ្ញើជូន ខៀវ សំផន និង អៀង សារី"

ទាំងបីច្បាប់ស្ថិតនៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា។

១១. សហព្រះរាជអាជ្ញាបានរំឭកថា ក្នុងករណីមួយចំនួន អង្គជំនុំជម្រះអនុញ្ញាតឲ្យទទួលយកឯកសារមិនមែនជាឯកសារថ្មី ជាអាទិ៍ នៅពេលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យវិភាគឯកសារដែលស្នើសុំរួមគ្នានឹងប្រភពព័ត៌មានផ្សេងទៀត ដែលមានស្រាប់នៅក្នុងសំណុំរឿង ហើយមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ[8]។ សហព្រះរាជអាជ្ញាយល់ថា លិខិតទីបីរបស់អង្គការលើកលែងទោសអន្តរជាតិ (ឯកសារ D84/2.5) ដែលមាននៅក្នុងបញ្ជីបឋមរបស់ខ្លួន គាំទ្រដល់ការទទួលយកលិខិតពីរច្បាប់ទៀត ដែលខ្លួនស្នើសុំនៅពេលនេះ[9]។ មេធាវីការពារក្តីនឹងបង្ហាញនៅផ្នែកទីពីរថាគ្មានឯកសារណាមួយក្នុងចំណោមឯកសារទាំងបីនេះមានភាពពាក់ព័ន្ធនោះទេ ហើយឯកសារទាំងបីនេះគប្បីត្រូវច្រានចោល អនុលោមតាមវិធាន ៨៧(៣)។

១២. មេធាវីការពារក្តីយល់ស្របជាមួយសហព្រះរាជអាជ្ញា ក្នុងការកត់សម្គាល់ថា អង្គជំនុំជម្រះមានភាពបត់បែនពាក់ព័ន្ធនឹងការទទួលយកឯកសារ ដែលមិនមាននៅក្នុងបញ្ជីរបស់ភាគីពីមុន។ ក៏ប៉ុន្តែប្រវត្តិនៃនីតិវិធីបង្ហាញឲ្យឃើញថា អង្គជំនុំជម្រះអនុវត្តវិធានផ្សេងគ្នា ចំពោះសំណើរបស់មេធាវីការពារក្តី និងសំណើរបស់សហព្រះរាជអាជ្ញា។

១៣. ដើម្បីជាការរំឭក លក្ខណៈវិនិច្ឆ័យយ៉ាងតឹងរ៉ឹង ដែលអង្គជំនុំជម្រះបានកំណត់ពីមុន ត្រូវបានអនុវត្តបន្ទាប់ពីមានសំណើពីសហព្រះរាជអាជ្ញាឲ្យ *"ហាមមេធាវីការពារក្តី នួន ជា មិនឲ្យបង្ហាញឯកសារដែលមិនត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងបញ្ជីដែលបានដាក់ អនុលោមតាមដីកាមុនៗរបស់អង្គជំនុំជម្រះ"*[10]។ អង្គជំនុំជម្រះបានបញ្ជាក់ជូនភាគីថា *"ចំពោះឯកសារដែលពុំត្រូវបានដាក់ទាន់កាល*

---

ស៊ើបសួរជាក់លាក់ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៨ ឯកសារ D84។

[8] ឯកសារ E265 កថាខណ្ឌ ១៦។

[9] ឯកសារ E265 កថាខណ្ឌ ៧ និង ១៧។

[10] សំណើរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការខកខានជាលើកទីពីររបស់ នួន ជា ក្នុងការមិនបានអនុវត្តតាមដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដើម្បីផ្តល់បញ្ជីឯកសារ និងវត្ថុតាងដែលខ្លួនមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១១ ឯកសារ E109/5 កថាខណ្ឌ ៣២។

*កំណត់នាពេលកន្លងមក ឯកសារនោះអាចត្រូវបានប្រកាសទទួលយកនាពេលក្រោយ តែក្នុងករណីឯកសារនោះឆ្លើយតបទៅនឹងលក្ខខ័ណ្ឌដ៏តឹងរ៉ឹងជាទីបំផុត ដូចមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង គឺត្រូវបង្ហាញថា ទោះបីជាមានការខ្វះខ្នែងអស់ពីលទ្ធភាពយ៉ាងណាក៏ដោយ ក៏ឯកសារនោះមិនអាចផ្តល់ជូនភាគីបានតាមកាលកំណត់ ហើយការទទួលយកឯកសារដែលដាក់យឺតពេលនោះ គឺជាការចាំបាច់ដើម្បីផលប្រយោជន៍យុត្តិធម៌។ ដូច្នេះ សំណើសុំឱ្យទទួលយកឯកសារភាគច្រើន ដែលដាក់យឺតពេល មានឱកាសតិចតួចស្តួចស្តើងក្នុងការទទួលបានការអនុញ្ញាត"*[11]។

១៤. ទោះជាយ៉ាងណា លក្ខណៈវិនិច្ឆ័យទាំងនេះហាក់ដូចជាមិនអនុវត្តចំពោះសហព្រះរាជអាជ្ញាទេ។

១៥. តួយ៉ាងដូចជា ទោះបីជាអង្គជំនុំជម្រះទទួលស្គាល់ថា សហព្រះរាជអាជ្ញាមិនបាន *"ខ្វះខ្នែងអស់ពីលទ្ធភាព"* ក៏អង្គជំនុំជម្រះអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដាក់សៀវភៅមួយក្បាល ដោយសំអាងហេតុថា សៀវភៅនោះ *"មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ"* ជាមួយខ្សែភាពយន្តឯកសារមួយដែលដើមបណ្តឹងរដ្ឋប្បវេណីបានដាក់នៅក្នុងបញ្ជីឯកសាររបស់ខ្លួន ហើយ *"អង្គជំនុំជម្រះត្រូវពិនិត្យមើលប្រភពទាំងនេះរួមគ្នា ដើម្បីជាផលប្រយោជន៍យុត្តិធម៌"*[12]។

១៦. សហព្រះរាជអាជ្ញាក៏អាចដាក់ឲ្យពិភាក្សាដេញដោលនូវឯកសារមួយ ដែលមាននៅក្នុងសំណុំរឿងស៊ើបអង្កេត ប៉ុន្តែ មិនមាននៅក្នុងបញ្ជីឯកសាររបស់ខ្លួន។

១៧. ឧទាហរណ៍ នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាអះអាងថាបាន *"រកឃើញនៅក្នុង Zylab"* នូវឯកសារមួយដែលទំនងជាប្រវត្តិរូបរបស់ TCW-64[13] ជាសាក្សីដែលខ្លួនបានស្នើសុំឱ្យកោះហៅ កាលពីមួយឆ្នាំមុន[14]។ ផ្ទុយទៅវិញ ឯកសារនេះមានស្រាប់ក្នុងសំណុំរឿងស៊ើប

---

[11] ឯកសារ E131/1 ទំព័រ ៦។

[12] ឯកសារ E190 កថាខណ្ឌ ៣២។

[13] សំណើរបស់សហព្រះរាជអាជ្ញា យោងតាមវិធាន ៨៧(៤) ទាក់ទងនឹងប្រវត្តិរូបសាក្សី TCW-64 ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារ E203 កថាខណ្ឌ ៣។

[14] ឧបសម្ព័ន្ធ ៣៖ បញ្ជីឈ្មោះសាក្សី៖ ការិយាល័យសហព្រះរាជអាជ្ញា ឯកសារ E9/4.3 ទំព័រ ៣៣។

អង្កេត តាំងតែពីឆ្នាំ២០០៩ មកម្ល៉េះ។ ក៏ប៉ុន្តែ នៅក្នុងសវនាការ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១២ ប្រធានអង្គជំនុំជម្រះបានប្រកាសថា *"ខ្លឹមសារនៃឯកសារនេះមានភាពពាក់ព័ន្ធ ហេតុនេះហើយបាន ជាអង្គជំនុំជម្រះអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដាក់ឲ្យពិភាក្សាដេញដោល"*[15]។ នៅថ្ងៃនោះ អង្គជំនុំជម្រះមិនបានតម្រូវឲ្យសហព្រះរាជអាជ្ញា *"បង្ហាញថាទោះបីជាមានការខ្វះខែងអស់ពីលទ្ធភាព យ៉ាងណាក៏ដោយ ក៏ឯកសារនោះមិនអាចផ្ដល់ជូនភាគីបានតាមកាលកំណត់ ហើយការទទួលយក ឯកសារដែលដាក់យឺតពេលនោះ គឺជាការចាំបាច់ដើម្បីផលប្រយោជន៍យុត្តិធម៌"*[16]។

១៨. ក្នុងស្ថានភាពស្រដៀងគ្នានេះ អង្គជំនុំជម្រះបានប្រកាន់យកវិធីសាស្ត្រមួយទៀត។ ជាក់ស្ដែង នៅពេលស្ដាប់ចម្លើយសាក្សី ROCKOFF Al មេធាវីការពារក្ដីលោក ខៀវ សំផន បានស្នើសុំប្រើប្រាស់ឯកសារមួយ ដែលមាននៅក្នុងសំណុំរឿងស៊ើបអង្កេត តាំងពីខែ មេសា ឆ្នាំ ២០១០។ ទោះបីជាមេធាវីការពារក្ដីបានបង្ហាញអំពីភាពពាក់ព័ន្ធនៃឯកសារនេះក៏ដោយ[17] ហើយទោះបីជាគ្មានភាគីណាមួយជំទាស់ទៅនឹងការប្រើប្រាស់ឯកសារនេះក៏ដោយ[18] ក៏ប្រធានអង្គជំនុំជម្រះបានឆ្លើយតបថា *"ឯកសារដែលមេធាវីការពារក្ដីលោក ខៀវ សំផន បានស្នើសុំនេះ មិនមាននៅក្នុងបញ្ជីឯកសាររបស់ខ្លួន ក៏ដូចជានៅក្នុងបញ្ជីឯកសាររបស់ភាគីនានាដែលពាក់ព័ន្ធ ហើយអង្គជំនុំជម្រះធ្លាប់បានអនុវត្តរួចហើយ មិនអនុញ្ញាតឲ្យប្រើប្រាស់ឯកសារប្រភេទនេះ ក្នុងការសួរដេញដោលសាក្សី ឬក៏អ្នកជំនាញនោះទេ"*[19]។

១៩. សូមរំឭកថា នៅពេលដាក់បញ្ជីឯកសារបឋម អង្គជំនុំជម្រះបានណែនាំភាគីឲ្យដាក់តែឯកសារណាដែលមានភាពពាក់ព័ន្ធ សម្រាប់សាក្សីដែលខ្លួនចង់ឲ្យកោះហៅប៉ុណ្ណោះ[20]។ សហព្រះរាជអាជ្ញាបាន

---

[15] ប្រតិចារឹកសវនាការ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ E1/81.1 ទំព័រ ៦២ បន្ទាត់ ៦-៨។

[16] ឯកសារ E131/1 ទំព័រ ៦។

[17] ប្រតិចារឹកសវនាការ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ ឯកសារ E1/166.1 ទំព័រ ៣៥ បន្ទាត់ ៤-៩។

[18] ដូចយោងខាងលើ ទំព័រ ៣៤ បន្ទាត់ ២៥។ មេធាវីការពារក្ដីបានដាក់ឯកសារនេះនៅក្នុងប្រព័ន្ធ interface តាមការណែនាំរបស់អង្គជំនុំជម្រះ។

[19] ដូចយោងខាងលើ ទំព័រ ៣៥ បន្ទាត់ ១៤-១៧។

[20] អ៊ីមែលរបស់លោកស្រី Susan LAMB ផ្ញើជូនភាគី ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១ វេលាម៉ោង ១៥ និង ៣៤ នាទី កម្មវត្ថុ៖ *"ចម្លើយតបទៅនឹងសំណួរដែលបានលើកឡើងក្នុងកិច្ចប្រជុំរៀបចំសវនាការ"* ឯកសារ E9/25.1.1 ទំព័រ ២ *"វិសាលភាពនៃ*

ស្នើសុំឱ្យកោះហៅសាក្សី TCW-64[21]។ មេធាវីការពារក្តីលោក ខៀវ សំផន មិនបានស្នើសុំឱ្យកោះហៅលោក ROCKOFF Al នោះទេ។

២០. ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាទទួលបានការអនុញ្ញាតឱ្យប្រើប្រាស់រូបថតមួយឈុត ដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា នៅពេលស្តាប់ចម្លើយលោក ROCKOFF Al នាថ្ងៃដដែលនោះ ខណៈដែលរូបថតទាំងនេះមិនមាននៅក្នុងសំណុំរឿងស៊ើបអង្កេត និងមិនស្ថិតនៅក្នុងបញ្ជីរបស់ខ្លួននោះឡើយ[22] (ចៅក្រម Jean-Marc LAVERGNE ថែមទាំងអាចប្រើប្រាស់រូបថតដែលគាត់ស្វែងរកបាននៅក្នុងអ៊ីនធឺណិតទៀតផង)។

២១. ការប្រព្រឹត្តមិនស្មើភាពគ្នាបែបនេះរវាងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី មិនត្រូវបានបញ្ជាក់ហេតុផលនោះទេ និងមិនគប្បីមានតទៅទៀតឡើយ។ អាស្រ័យហេតុនេះ សូមអង្គជំនុំជម្រះមេត្តាកត់សម្គាល់ថា លក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៤) មិនត្រូវបានបំពេញនោះទេ។

## II- លក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៣) មិនត្រូវបានបំពេញ

២២. ប្រសិនបើអង្គជំនុំជម្រះសម្រេចថាលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៤) ត្រូវបានបំពេញ អង្គជំនុំជម្រះអាចអនុញ្ញាតឱ្យដាក់ឯកសារពិភាក្សាដេញដោលបាន ទាល់តែលក្ខណៈវិនិច្ឆ័យនៃវិធាន ៨៧(៣) ត្រូវបានបំពេញផងដែរ។

២៣. វិធាន ៨៧(៣) អនុញ្ញាតឱ្យអង្គជំនុំជម្រះបដិសេធឯកសារភស្តុតាងមួយចំនួនបាន៖
*"៣. អង្គជំនុំជម្រះសាលាដំបូង ធ្វើសេចក្តីសម្រេច ដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ប្រសិនបើភាគីយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬប្រសិនបើអង្គជំនុំ*

---

*កាតព្វកិច្ចក្នុងការដាក់បញ្ជីឯកសារ/វត្ថុតាង"*។

[21] ឧបសម្ព័ន្ធ ៣៖ បញ្ជីឈ្មោះសាក្សី៖ ការិយាល័យសហព្រះរាជអាជ្ញា ឯកសារ E9/4.3 ទំព័រ ៣៣។

[22] ប្រតិចារឹកសវនាការ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ ឯកសារ E1/165.1 ទំព័រ ២៧ បន្ទាត់ ១៩-២៥ និងទំព័រ ៥៨ បន្ទាត់ ១៣-១៩។

*ជម្រះខ្លួនឯង យកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខភាគី។ ភស្តុតាងដែលមាននៅក្នុងសំណុំរឿងត្រូវបានចាត់ទុកថា បានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬភាគី បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ត្រូវបានអាន ឬត្រូវបានកំណត់អត្តសញ្ញាណយ៉ាងសមស្របក្នុងសវនាការ។ អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថា៖*

*ក- មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា*

*ខ- មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ*

*គ- មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង*

*ឃ- ច្បាប់មិនអនុញ្ញាត ឬ*

*ង- មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍”។*

២៤. សហព្រះរាជអាជ្ញាលើកឡើងថា លិខិតទាំងពីរច្បាប់ដែលខ្លួនស្នើសុំដាក់ឲ្យពិភាក្សាដេញដោលមានភាពពាក់ព័ន្ធយ៉ាងខ្លាំង ពីព្រោះលិខិតទាំងនេះអាចឲ្យបង្ហាញអំពីតួនាទីរបស់លោក ខៀវ សំផន និងលោក អៀង សារី ក៏ដូចជាការដឹងឮរបស់ជនជាប់ចោទទាំងពីរអំពីភាពសាហាវយង់ឃ្នងក្នុងទ្រង់ទ្រាយធំ និងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[23]។ សហព្រះរាជអាជ្ញាក៏បានអះអាងផងដែរឯកសារស្រដៀងគ្នាទាំងពីរនេះ មានស្រាប់នៅក្នុងសំណុំរឿង[24]។

២៥. មេធាវីការពារក្តីលោក ខៀវ សំផន សូមលើកឡើងថា លិខិតទាំងនេះមិនមានភាពពាក់ព័ន្ធ និងមិនអាចបញ្ជាក់អង្គហេតុ ដូចដែលសហព្រះរាជអាជ្ញាបានអះអាងនោះទេ។

២៦. ជាក់ស្តែង លិខិតទីមួយ ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ត្រូវបានផ្ញើជូនលោក ប៉ែន នុត (ចម្លងជូនលោក ខៀវ សំផន...) តាមរយៈស្ថានបេសកកម្មរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ប្រចាំទីក្រុងប៉ារីស[25]។ លិខិតទីពីរ ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៦ ត្រូវបានផ្ញើជូនលោក ខៀវ សំផន

---

[23] ឯកសារ E265 កថាខណ្ឌ ៦។

[24] ឯកសារ E265 កថាខណ្ឌ ៧។

[25] លិខិតរបស់អង្គការលើកលែងទោសអន្តរជាតិ ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ឯកសារ D84/2.3 ទំព័រ ១។

តាមរយៈស្ថានបេសកកម្មរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ប្រចាំទីក្រុងប៉ារីស[26]។ នៅកាលបរិច្ឆេទទាំងពីរនេះ លោក ខៀវ សំផន មិនស្នាក់នៅទីក្រុងប៉ារីសនោះទេ។ ម្យ៉ាងវិញទៀត ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ លោក ខៀវ សំផន មិនធ្លាប់ទៅប្រទេសបារាំងទាល់តែសោះ។ បើគ្មានសាក្សីមកអះអាងថាបានយកលិខិតទាំងនេះនៅទីក្រុងប៉ារីស និងបានប្រគល់ជូនលោក ខៀវ សំផន គ្មានភ័ស្តុតាងណាអាចបញ្ជាក់ថា លោក ខៀវ សំផន ពិតជាបានទទួលលិខិតទាំងនេះទេ។ ឯកសារទាំងនេះអាចត្រឹមតែបង្ហាញថា អង្គការលើកលែងទោសអន្តរជាតិបានផ្ញើលិខិតទាំងនេះប៉ុណ្ណោះ។ ដូច្នេះ ឯកសារទាំងនេះមិនមានភាពពាក់ព័ន្ធនោះទេ។

២៧. ឯកសារទីបី ដែលសហព្រះរាជអាជ្ញាប្រើប្រាស់ ដើម្បីគាំទ្រដល់គំនិតរបស់ខ្លួន គឺជាលិខិតទីបីរបស់អង្គការលើកលែងទោសអន្តរជាតិ ផ្ញើជូនលោក ខៀវ សំផន ដោយប្រើពាក្យពេចន៍ដូចតទៅ៖ *"គោរពជូនលោក ខៀវ សំផន ប្រធានគណៈប្រធានរដ្ឋ ទីក្រុងភ្នំពេញ កម្ពុជាប្រជាធិបតេយ្យ"*[27]។ លិខិតនេះចុះកាលបរិច្ឆេទ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៧៧។ ដូចគ្នាផងដែរ ឯកសារនេះមិនអាចឱ្យបង្ហាញថាលោក ខៀវ សំផន ដឹងឮអំពីឧក្រិដ្ឋកម្មបានឡើយ លើកលែងតែសហព្រះរាជអាជ្ញាអាចបង្ហាញអំពីអត្ថិភាពនៃសេវាប្រៃសណីយ៍ពិតប្រាកដក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលអនុញ្ញាតឱ្យប្រគល់លិខិតនេះជូនលោក ខៀវ សំផន។ បើគ្មានសាក្សីមកបញ្ជាក់ថាលោក ខៀវ សំផន បានទទួលលិខិតនេះ ឯកសារនេះមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាងនោះទេ។ ម្យ៉ាងវិញទៀត នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា *"យោងតាម សួង ស៊ីគឿន ព័ត៌មានក្រៅប្រទេសត្រូវបានផ្សព្វផ្សាយ តាមរយៈស្ថានទូតនៅទីក្រុងប៉េកាំង ហើយការទាក់ទងអាចមកពីបក្ស ឬពីរដ្ឋាភិបាល ឬដោយផ្ទាល់ពី ប៉ុល ពត"*[28]។ ក៏ប៉ុន្តែ លោក សួង ស៊ីគឿន បានមកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ ហើយសហព្រះរាជអាជ្ញាមិនបានចោទសួរគាត់ពីប្រធានបទនេះ ឬពីលទ្ធភាពរបស់អង្គការលើកលែងទោសអន្តរជាតិក្នុងការផ្ញើលិខិតដោយផ្ទាល់ទៅកម្ពុជាប្រជាធិបតេយ្យ នោះទេ។

---

[26] លិខិតរបស់អង្គការលើកលែងទោសអន្តរជាតិ ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៦ ឯកសារ D84/2.4 ទំព័រ ១។

[27] លិខិតរបស់អង្គការលើកលែងទោសអន្តរជាតិ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៧៧ ឯកសារ D84/2.5 ទំព័រ ១។

[28] ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D427 កថាខណ្ឌ ៨៦។

២៨. ដូច្នេះ ផ្ទុយនឹងការអះអាងរបស់សហព្រះរាជអាជ្ញា ឯកសារទាំងនេះមិនមានភាពពាក់ព័ន្ធ និងមិនអាចបញ្ជាក់ភ័ស្តុតាងអំពីការចោទប្រកាន់របស់សហព្រះរាជអាជ្ញានោះទេ។

២៩. **អាស្រ័យហេតុនេះ** មេធាវីការពារក្តីលោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **បដិសេធ** សំណើរបស់សហព្រះរាជអាជ្ញា

**ឬ**

- **សម្រេច** មិនទទួលយកឯកសារ D84/2.3, D84/2.4 និង D84/2.5

**ក្នុងករណីណាក៏ដោយ**

- **កំណត់** វិធានជាក់លាក់ និងយុត្តិធម៌ ពាក់ព័ន្ធនឹងការទទួលយកឯកសារថ្មី ដែលត្រូវអនុវត្តដូចគ្នាចំពោះភាគីទាំងអស់។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | ទីក្រុងភ្នំពេញ | |
| | មេធាវី Anta GUISSÉ | ទីក្រុងភ្នំពេញ | |
| | មេធាវី Arthur VERCKEN | ទីក្រុងភ្នំពេញ | |
| | មេធាវី Jacques VERGÈS | ទីក្រុងប៉ារីស | |